ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN No : 408
Date: 06.09.11 Time: 3:10
For : GMAC

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ១៦៧ ក.ប/ស.ជ.ណ

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង
# ស្តីពី
# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
# និង
# ការឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ

យោងតាមលិខិតលេខ ៣២០/១១ គ.ជ.ប ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែ កញ្ញា ដល់ថ្ងៃទី១៥ ខែ តុលា ឆ្នាំ២០១១ និងយោងតាមប្រកាសរបស់ក្រសួងលេខ ១៩៦ កប/ប្រក. ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១០ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ មេត្តាអនុញ្ញាតឲ្យកម្មករនិយោជិតបានឈប់សម្រាកតាមកាលបរិច្ឆេទ ដូចខាងក្រោម ៖

**១-ការអនុញ្ញាតឲ្យកម្មករនិយោជិតបានទៅ ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

១-ថ្ងៃ ព្រហស្បត្តិ៍ ទី ២២ និងថ្ងៃ សុក្រ ទី ២៣ ខែ កញ្ញា ឆ្នាំ២០១១ សម្រាប់កម្មករនិយោជិតធ្វើការនៅរាជធានីភ្នំពេញ ត្រូវចេញពីរាជធានីភ្នំពេញទៅ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប និងខេត្តព្រះសីហនុ។

២-ថ្ងៃ ពុធ ទី ២១ ថ្ងៃ ព្រហស្បត្តិ៍ ទី ២២ និងថ្ងៃ សុក្រ ទី ២៣ ខែ កញ្ញា ឆ្នាំ២០១១ សម្រាប់កម្មករនិយោជិតធ្វើការនៅរាជធានីភ្នំពេញ ទៅខេត្តផ្សេងៗក្រៅពីខេត្ត ដែលចែងក្នុងចំណុចទី១ ខាងលើ ។

៣-ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅក្នុងខេត្តដទៃទៀត ក្រៅពីរាជធានីភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតតាមកំណត់ដូចចែងក្នុងចំណុចទី១ និងទី២ ខាងលើដែរ ដោយយកខេត្តនីមួយៗ ធ្វើជាមូលដ្ឋានដើម ដូចគ្នានឹងរាជធានីភ្នំពេញដែរ ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**២-ការអនុញ្ញាតឲ្យកម្មករនិយោជិតបានឈប់សម្រាកក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ**

យោងតាមច្បាប់ស្តីពីការងារ និងប្រកាសរបស់ក្រសួងលេខ ១៩៦ កប/ប្រក. ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១០ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល និងដើម្បីបង្កលក្ខណៈងាយស្រួលដល់បងប្អូនកម្មករនិយោជិតក្នុងឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ សូមលោក លោកស្រី ម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថាន ត្រូវអនុញ្ញាតឲ្យកម្មករនិយោជិតទាំងអស់របស់ខ្លួនឈប់សម្រាកដោយមានប្រាក់ឈ្នួលនាឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ ក្នុងកំឡុងពេលបីថ្ងៃគឺ ថ្ងៃទី ២៦-២៧ និងថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១១។

**៣-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមគូសបញ្ជាក់ប្រការមួយចំនួនដែលត្រូវយកចិត្តទុកដាក់គឺ៖**

ក- រាល់ការអនុញ្ញាតច្បាប់ជូនកម្មករនិយោជិត ដូចមានចែងខាងលើនេះ និយោជកត្រូវរក្សាទុកប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនកម្មករនិយោជិតនៅដដែល ។

ខ- ចំពោះកម្មករនិយោជិត ដែលអវត្តមានហួសពីច្បាប់អនុញ្ញាត ដូចមានចែងខាងលើនេះ ត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន ។

គ- ខិតខំរៀបចំបើកប្រាក់ឈ្នួលឲ្យកម្មករនិយោជិតឲ្យបានមុនថ្ងៃទៅពិនិត្យបញ្ជីឈ្មោះ ឬ ទៅចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងបុណ្យភ្ជុំបិណ្ឌ ។

ឃ- បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ពេលទេ សូមអនុញ្ញាតឲ្យកម្មករនិយោជិតទទួលប្រាក់ឈ្នួលមួយភាគជាបុរេប្រទានមុនពេលទៅពិនិត្យបញ្ជីឈ្មោះ ឬទៅចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងបុណ្យភ្ជុំបិណ្ឌ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ព្រមទាំងកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  " ដើម្បីជូនជ្រាប "
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
  " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- កាលប្បវត្តិ - ឯកសារ